**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥៨_០១២_២៣៣.ធ.ជ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែឧសភា ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជន ឲ្យបានជ្រាបថាធនាគារជាតិនៃកម្ពុជានឹងធ្វើការជ្រើសរើសបុគ្គលិកទាំង០២ភេទ ដែលមានកម្រិតសញ្ញាបត្របរិញ្ញាបត្រ **ផ្នែកគណនេយ្យ** ឬ **ផ្នែកធនាគារ** ចំនួន ១០រូប តាមរយៈការធ្វើតេស្ត និងសម្ភាសន៍ផ្ទាល់មាត់។ បេក្ខជនត្រូវមានលក្ខណៈសម្បត្តិផ្សេងៗទៀតដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរ

២- អាយុចន្លោះពី ១៨ ទៅ ៣០ឆ្នាំ

៣- ចេះភាសាអង់គ្លេស និងកុំព្យូទ័រ

៤- មានកាយសម្បទាគ្រប់គ្រាន់ (វិញ្ញាបនប័ត្របញ្ជាក់ពីមន្ទីរពេទ្យការងារ)

- មុខវិជ្ជាប្រឡង ៖
    - \+ ចំណេះដឹងទូទៅនិងធនាគារ
    - \+ ជំនាញគណនេយ្យ
    - \+ ភាសាអង់គ្លេស

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលំអិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិក **«ធនាគារជាតិនៃកម្ពុជា»** ដែលមានទីតាំងនៅដីឡូត៍លេខ ២២-២៤ តាមបណ្តោយមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១៥:០០នាទីរសៀល រៀងរាល់ម៉ោងធ្វើការ ។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ ថ្ងៃសុក្រ ទី២៩ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោង ១១ : ០០នាទី
- កាលបរិច្ឆេទនិង ទីកន្លែងប្រឡង ៖ ជូនដំណឹងនៅពេលក្រោយ ។

**ក.ប.ទេសាភិបាល**

**អគ្គលេខាធិការ**

ស៊ុំ.សន្និសិដ្ឋ